# អន្តរប្បីរី

## សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ សូមតុលាការកាត់ទោសខ្មែរក្រហម រកយុត្តិធម៌ប្រគេនព្រះសង្ឃព្រះពុទ្ធសាសនា ដែលត្រូវខ្មែរក្រហមធ្វើគត់ ។

website: www.hoksavann.org

ថ្ងៃទី១១ តុលា ២០០៧



បន្ទាប់ពីខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧មេសា១៩៧៥ ខ្មែរក្រហមបានដេញប្រជាពលរដ្ឋខ្មែរនិ-ងព្រះសង្ឃចេញពីទីក្រុងភ្នំពេញ ។ ព្រះសង្ឃបានចេញពីវត្តធ្វើដំណើរច្រូកច្របល់ជាមួយប្រជាពលរដ្ឋខ្មែរដោយគ្មានទិសដៅ ។ ដោយសារព្រះសង្ឃរស់នៅដោយសារគេប្រគេនពេលដែលចេញដំណើរនោះគ្មានអ្វីឆាន់ទេ ដោយពុទ្ធបរិស័ទខ្មែរក៏លំបាកវេទនា គ្មានយកអ្វីទៅតាមខ្លួនបានច្រើនទេពេលគេដេញនោះ មានអ្នកខ្លះធ្វើដំណើរដោយព្រាត់ប្រាស់បងប្អូនកូនចៅស្វាមីភរិយា គ្មានអ្នកណាជួយអ្នកណាបានទេ យកតែប្រាសអាយុរៀងខ្លួន ព្រោះខ្មែរក្រហមដេញចេញដោយបង្ខំ បើអ្នកណាចេញមិនទាន់ឬចេញយឺត ខ្មែរក្រហមបានបាញ់សម្លាប់នៅនឹងកន្លែងតែម្តង។ ពត៌មានដែលបានពោលមកនេះ នឹងរៀបរាប់ទៅមុខទៀត គឺបានមកពីប្រជាពលរដ្ឋខ្មែររាប់រយនាក់បាននិយាយប្រាប់ ។ នៅតាមផ្លូវព្រះសង្ឃបានទទួលចង្ហាន់ខ្លះពីពុទ្ធបរិស័ទ ដែលបានបេះពីមាត់ពឹកពីការលំបាកវេទនារបស់ខ្លួន ។ ព្រះសង្ឃខ្លះលំបាកវេទនាពេក ក៏ត្រូវបង្ខំព្រះទ័យសឹកតាមផ្លូវ ព្រះសង្ឃភាគច្រើនដែលស្រឡាញ់ព្រះពុទ្ធសាសនា ស្រឡាញ់ភេទអ្នកបួស ក៏ទ្រាំលំបាកវេទនានៅពេលដែលគេដេញនោះ ។

ខ្មែរក្រហមពុំមែនដេញប្រជាពលរដ្ឋតែនៅទីក្រុងភ្នំពេញទេ គឺដេញចេញពីទីក្រុងគ្រប់ខេត្តទាំងអស់ក្នុងប្រទេសទាំងមូល នៅថ្ងៃបន្តបន្ទាប់មកទៀត ។ ពេលដែលដេញប្រ

ជាពលរដ្ឋនិងព្រះសង្ឃចេញពីផ្ទះពីវត្តនោះ ខ្មែរក្រហមគ្មានធ្វើផែនការផ្តល់ស្បៀងនិងទីជំរក យានជំនិះធ្វើដំណើរ ពេទ្យព្យាបាលជម្ងឺសោះឡើយ គឺដេញចេញដូចដេញសត្វតិរច្ឆាន ឲ្យធ្វើដំណើរចេញទៅស្លាប់រស់តាមយថាកម្មរបស់ខ្លួន ។ ព្រះសង្ឃចាស់ជរាខ្លះដួលសុគតតាមផ្លូវ ដោយសារហេវហត់អស់កម្លាំងដាច់ចង្ហាន់ ធ្វើដំណើរផ្លូវឆ្ងាយ ត្រូវភ្លៀងត្រូវកំដៅថ្ងៃ គ្មានអ្វីការពារខ្លួនព្រះអង្គ ។

ព្រះសង្ឃមានអាពាធធ្ងន់ដែលសឹងនៅមន្ទីរពេទ្យព្រះសង្ឃនៅទីក្រុងភ្នំពេញ ដែលនិមន្តចេញពុំរួច ខ្មែរក្រហមបានទុកចោលគ្មានពេទ្យព្យាបាលបន្ត គ្មានប្រគេនចង្ហាន់ត្រូវសុគតទាំងអស់ ។

សម្តេចព្រះសុមេធាធិបតី ហួត-តាត ព្រះសង្ឃរាជគណៈមហានិកាយ និងមន្ត្រីសង្ឃ ព្រមទាំងព្រះសង្ឃជាព្រះថេរៈបញ្ញវន្ត ដូចជាព្រះតេជព្រះគុណ សូ-ហាយ, ព្រះតេជព្រះគុណ គឹម-តូ, ព្រះតេជព្រះគុណ ប៉ាង-ខាត់, ព្រះតេជព្រះគុណ ខៀវ-ជុំ ជាដើម បានត្រូវខ្មែរក្រហមធ្វើគត់ជាបន្តបន្ទាប់គ្នា នៅពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេ-ញ ។ គេពុំទាន់ដឹងច្បាស់ថា ខ្មែរក្រហមបានធ្វើគត់មន្ត្រីសង្ឃទាំងនោះ តាមវិធីរបៀបណា ហើយកប់ព្រះអង្គនៅទីណាទេ អ្នកស្រុកដឹងឮគ្រាន់តែនិយាយថា មន្ត្រីសង្ឃទាំងនោះត្រូវសុគតដោយវេទនាជាទីបំផុត ដោយខ្មែរក្រហមធ្វើទារុណកម្ម ជាពិសេសសម្តេច ហួត-តាត ។ តាមពត៌មានថា ខ្មែរក្រហមបានសួរចម្លើយផ្ចាញ់ផ្ចាល ហើយបង្អត់ចង្ហាន់ ទីបំផុតពួកវាចងអូសតាមឡាន បែកឈាមរយះស្បែក រហូតដាច់ខ្យល់សុគតទៅ ។

ចំពោះរឿងនេះ យើងបានស្នើទៅលោក ឆាំង-យុ អ្នកស្វែងរកការពិតនៃឧក្រិដ្ឋកម្មខ្មែរក្រហម ឲ្យជួយស្រាវជ្រាវ អំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមមកលើព្រះសង្ឃ លោក ឆាំង-យុ បានឆ្លើយតាមទូរសារ (fax) ថា គាត់ស្រាវជ្រាវបានខ្លះហើយ ។

ចំណែកព្រះតេជព្រះគុណ ប៉ុណ្យ-សម្អាជ ព្រះវិនរត ព្រះមេគណខេត្តបាត់ដំបងតាមយោធាម្នាក់និយាយថា ខ្មែរក្រហមបានចាប់ព្រះតេជព្រះគុណ ប៉ុណ្យ-សម្អាជ ពីវត្តពោធិវាល ទៅធ្វើគត់នៅវាលបែកចានទីក្រុងបាត់ដំបង ។ ដំបូងខ្មែរក្រហមពីរនាក់ឲ្យលោកជីករណ្តៅ ។ ដោយដឹងថាពួកវាធ្វើគត់ហើយ លោកមានថេរដីកាទៅកាន់យោធាខ្មែរក្រហមទាំងពីរនាក់នោះរបៀបអង្វរថា មិនចាំបាច់ធ្វើគត់អាត្មាទេ បើមិនចង់ឲ្យមានព្រះសង្ឃទេ គ្រាន់តែឲ្យអាត្មាសឹកបានហើយ ។ ដោយដឹងថាខ្មែរក្រហមមិនព្រម ពិតជាធ្វើគត់លោកហើយ ទើបលោកសុំទៅខ្មែរក្រហមយោរយៅថា បើសម្លាប់អាត្មាហើយសូមយកចីពរទៅគ្របលើផ្នូរឲ្យអាត្មាផង ។ បន្ទាប់ពីឲ្យលោកជីករណ្តៅហើយ ខ្មែរក្រហមបានយកដំបងធ្វើពីបំពង់សង្កែ វាយលោកពីក្រោយទម្លាក់រណ្តៅនោះទៅ ហើយលុបដីតែម្តង មិនដឹងថាលោកត្រដរខ្យល់សុគតប៉ុន្មាននាទីក្រោយមកទេ ។ ពាក្យបណ្តាំ

របស់លោកថា បើលោកសុគតទៅ ឲ្យយកចីពរគ្របលើផ្នូរនោះ ខ្មែរក្រហមពុំបានធ្វើតាមឡើយ ។ ការដែលលោកសុំឲ្យខ្មែរក្រហមយកចីពរគ្របលើផ្នូរ ទំនងជាលោកចង់បង្ហាញឲ្យពុទ្ធបរិស័ទខ្មែរមើលឃើញថា ខ្មែរក្រហមធ្វើគត់ព្រះសង្ឃបំបាត់ពុទ្ធសាសនា ឲ្យពលរដ្ឋខ្មែរទាំងអស់ក្រោកឡើងប្រឆាំងនឹងខ្មែរក្រហម ។ ប៉ុន្តែបំណងនេះគ្មានបានប្រយោជន៍ឡើយ ព្រោះខ្មែរណាក៏ដឹងថា ខ្មែរក្រហមបំបាត់ព្រះពុទ្ធសាសនា ប៉ុន្តែពេលនោះពុំអាចធ្វើអ្វីកើត ។ ពត៌មាននេះជាពត៌មានគួរឲ្យជឿបាន ព្រោះអ្នកនិយាយរឿងនេះជាយោធាខ្មែរក្រហមម្នាក់ដែលនៅរស់ បានដឹងពីយោធាដែលធ្វើគត់លោក និយាយប្រាប់ ។ គួរទៅស្វែងរកផ្នូរដែលកប់លោកនៅវាលបែកចានទីក្រុងបាត់ដំបង ដើម្បីឲ្យដឹងការពិតទុកជាភស្តុតាង ។

ព្រះតេជព្រះគុណ កែវ-សាន អនុគណស្រុកបាត់ដំបង ក៏ត្រូវខ្មែរក្រហមធ្វើគត់មានទំនងដូចគ្នានឹងការធ្វើគត់ព្រះតេជព្រះគុណ ប៉ុណ្យ-សម្អាជ ដែរ ។ មន្ត្រីសង្ឃស្ទើរតែទាំងអស់ត្រូវខ្មែរក្រហមធ្វើគត់ ព្រោះបន្ទាប់ពីខ្មែរក្រហមអស់អំណាច ពុំឃើញមន្ត្រីសង្ឃទាំងនោះរស់នៅឡើយ ។

មុនខ្មែរក្រហមឡើងកាន់អំណាចថ្ងៃទី១៧មេសា១៩៧៥ ទីក្រុងភ្នំពេញមានប្រជាពលរដ្ឋខ្មែររស់នៅចំនួន២លាននាក់ ដែលក្នុងចំនួននោះ មានព្រះសង្ឃរាប់ម៉ឺនអង្គ ដែលភៀសព្រះអង្គមកពីខេត្តនានាដែលមានអសន្តិសុខ មករស់នៅទីក្រុងភ្នំពេញយ៉ាងកកកុញ ។

រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានសម្តេចនរោត្តម-សីហនុ ជាប្រធាន ជារដ្ឋាភិបាលនិរទេសនៅទីក្រុងប៉េកាំងប្រទេសចិនកុម្មុយនិស្ត បានចាត់ទុកព្រះសង្ឃនិងប្រជាពលរដ្ឋខ្មែរទីក្រុងភ្នំពេញ២លាននាក់នោះ ជាខ្មាំងក្រាញនៅជាមួយរបបលន់-នល់ ជាមុខសញ្ញាត្រូវដាក់ទណ្ឌកម្មនិងសម្លាប់ បន្ទាប់ពីពួកគេបានទទួលជ័យជំនះ ។ ដូច្នេះហើយ បានជាពេលដែលខ្មែរក្រហមបានដេញប្រជាពលរដ្ឋខ្មែរពីទីក្រុងភ្នំពេញអស់ហើយ សម្តេចនរោត្តម-សីហនុបានចូលមកដល់ទីក្រុងភ្នំពេញ បានទតឃើញទីក្រុងភ្នំពេញស្ងាត់ជ្រងំ គ្មានមនុស្សរស់នៅ ដូចជាទីក្រុងខ្មោច មិនឃើញព្រះសង្ឃមួយអង្គសោះ មិនបានឮព្រះអង្គសំដែងការតក់ស្លុតសោកស្តាយ ហើយប្រកាសប្រឆាំងនឹងខ្មែរក្រហមសោះឡើយ ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានរស់នៅជាមួយខ្មែរក្រហមក្នុងឋានៈជាព្រះប្រមុខរដ្ឋអស់មួយឆ្នាំទៀតផង ។ ដូច្នេះគេចាត់ទុកសង្គ្រាមនេះ ជាសង្គ្រាមគំនុំសងសឹក ។

តាមសំដីអ្នកស្រុកដែលរស់នៅសម័យខ្មែរក្រហមនិយាយថា បន្ទាប់ពីបានទទួលអំណាចពេញដៃហើយ ខ្មែរក្រហមមានផែនការផ្សឹកព្រះសង្ឃឲ្យអស់នៅចុងឆ្នាំ១៩៧៥ ។ ខ្មែរក្រហមចាប់ផ្តើមបំផ្លាញគម្ពីរក្បួនច្បាប់ព្រះពុទ្ធសាសនា មានគម្ពីរព្រះត្រៃបិដកជា

ដើម មានយកទៅដុតចោល យកមូរបារីជក់ បើសាស្ត្រាស្លឹករឹតយកទៅដេរម្លូកពាក់ ។ ព្រះពុទ្ធរូបបានត្រូវវាយកំទេចចោល យកទៅបោះចោលក្នុងស្រះទឹក ឬយកទៅកប់តាមផ្លូវឲ្យគេដើរជាន់ ។ កុដិសាលាព្រះវិហារខ្លះ បានត្រូវគេរុះរើចោល ខ្លះគេទុកធ្វើជង្រុកស្រូវ ធ្វើជាទ្រុងជ្រូក ធ្វើជាគុកសំរាប់ធ្វើទារុណកម្មមនុស្សជាដើម ។

និយាយអំពីវាសនាព្រះសង្ឃដែលគេដេញចេញពីទីក្រុងនានា ទៅរស់នៅក្នុងវត្តតាមជនបទស្រុកស្រែចំការ ដំបូងគេមិនទាន់បង្ខំឲ្យសឹកភ្លាមទេ ប៉ុន្តែគេប្រើមធ្យោបាយរឹតបន្តឹងបន្តិចម្តងៗឲ្យធុញទ្រាន់ និងពុំអាចស្ថិតនៅក្នុងផ្នួសកើត ដូចជាកន្លែងខ្លះបង្ខំឲ្យធ្វើស្រែចំការដូចជាគ្រហស្ថ ហាមពុទ្ធបរិស័ទប្រគេនចង្ហាន់ជាដើម ។ ព្រះសង្ឃខ្លះទ្រាំទ្រពុំបាន ក៏បង្ខំព្រះទ័យសឹកទៅ ។

នៅពេលបីខែបន្ទាប់ពីខ្មែរក្រហមទទួលអំណាច ព្រះសង្ឃនៅបិណ្ឌបាត្រ និងនៅទទួលចង្ហាន់ពីពុទ្ធបរិស័ទដែលយកទៅប្រគេនបាន ប៉ុន្តែបន្ទាប់ពីនោះ គឺនៅពេលដែលខ្មែរក្រហមបញ្ចូលប្រជាជនទាំងអស់នៅក្នុងសហករណ៍ គេចែករបបចំណីអាហារតាមបុគ្គលមួយរូបៗ ព្រះសង្ឃគ្មានលទ្ធភាព ដូចជានិមន្តបិណ្ឌបាត្របានដូចពីមុនឡើយ ដូ-ច្នេះត្រូវបង្ខំព្រះទ័យសឹកជាបន្តបន្ទាប់គ្នា ។ ដល់ពេលសឹកជិតអស់ នៅមានចំនួនតិចទើបខ្មែរក្រហមបង្ខំឲ្យសឹកទាំងអស់តែម្តង ។ ព្រះសង្ឃខ្លះក៏សឹកតាមការបង្ខំរបស់ខ្មែរក្រហម ព្រះសង្ឃខ្លះមិនព្រមសឹក ដោយការស្រឡាញ់ផ្នួសខ្លាំងពេក សុខចិត្តធ្វើការឲ្យអង្គការ ឲ្យតែព្រមឲ្យនៅបួស ត្រូវខ្មែរក្រហមនាំទៅធ្វើគត់បាត់ទៅ ។

ចំពោះព្រះសង្ឃដែលមានឋានន្តរស័ក្តិ និងព្រះសង្ឃដែលមានការចេះដឹង ត្រូវខ្មែរក្រហមស្រាវជ្រាវតាមវត្តនៅស្រុកស្រែចំការ យកទៅធ្វើគត់មុនបាត់ទៅហើយ ។ ព្រះសង្ឃដែលចេញពីទីក្រុង ដែលគេចាត់ថាជាតំបន់ខ្មាំងក្តី ព្រះសង្ឃដែលនៅតាមមូលដ្ឋាន ជាព្រះសង្ឃខ្មែរក្រហមក្តី ក្រៅពីយកទៅធ្វើគត់ ក៏ត្រូវសឹកទាំងអស់ ។ ដូច្នេះ ក្រៅពីព្រះសង្ឃខ្លះបានរត់រួចទៅប្រទេសថៃនៅដើមឆ្នាំ១៩៧៦ គ្មានព្រះសង្ឃសោះឡើយនៅប្រទេសកម្ពុជា គឺខ្មែរក្រហមផ្សឹកទាំងអស់ ។

ដូច្នេះ សូមតុលាការកាត់ទោសខ្មែរក្រហមរកយុត្តិធម៌ប្រគេនព្រះសង្ឃ ដែលត្រូវខ្មែរក្រហមធ្វើគត់នឹងត្រូវខ្មែរក្រហមផ្សឹក ជាអំពើឧក្រិដ្ឋកម្មមានលក្ខណៈអន្តរជាតិនិងលក្ខណៈជាតិ ដោយពិចារណាករណី៨យ៉ាង តើស្របករណីណាខ្លះគឺ ៖ អំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនិងមនុស្សជាតិ, ឧក្រិដ្ឋកម្មសង្គ្រាម, អំពើទាសភាពនិងការបង្ខំឲ្យធ្វើពលកម្ម, ការធ្វើទារុណកម្ម, ការបំផ្លិចបំផ្លាញវប្បធម៌ខ្មែរ, ការរើសអើងជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងសន្តិសុខសង្គម ។៚

❇